# របាយការណ៍

## ស្តីពី

## លទ្ធផលនៃការចុះសិក្សាស្រាវជ្រាវនិងរៀបចំលិខិតបទដ្ឋាន ស្តីពីការដោះស្រាយវិវាទនៅមូលដ្ឋាន

អនុវត្តតាមសេចក្តីសម្រេចលេខ ៣២៤៣ ស.ស.រ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការបង្កើតក្រុមការងារដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានស្តីពីការដោះស្រាយវិវាទនៅមូលដ្ឋានរបស់ក្រសួងមហាផ្ទៃនិងលិខិតបង្គាប់ការលេខ ២០៧ ល.ប.ក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ក្រុមការងារបានយកចិត្តទុកដាក់និងខិតខំប្រឹងប្រែងអនុវត្តការងារនិងភារកិច្ចរបស់ខ្លួន ទទួលបានលទ្ធផលមានដូចខាងក្រោមៈ

### ១.សេចក្តីផ្តើម

ទំនាស់គឺជាបញ្ហាដែលមិនអាចជៀសផុតបាននៅក្នុងជីវិត ។ វាគឺជាអ្វីដែលយើងបានជួបប្រទះនៅក្នុងជីវភាពប្រចាំថ្ងៃ ។ យើងទាំងអស់គ្នាសុទ្ធតែធ្លាប់ជួបប្រទះនូវទំនាស់នៅក្នុងទំនាក់ទំនងរបស់ពួកយើង ដូចជាជាមួយកូន ឪពុកម្តាយ បងប្អូន ប្តី ប្រពន្ធ មិត្តភក្តិ គ្រូបង្រៀន អ្នករួមការងារ អ្នកជិតខាង អាជីវករ អ្នកមានអំណាច និងរវាងប្រជាជាតិនិងប្រជាជាតិ។ល។

លទ្ធផលនៃទំនាស់គឺអាស្រ័យទៅលើតើអ្នកបង្កទំនាស់ដោះស្រាយទំនាស់តាមរបៀបណា ។ តួយ៉ាងទំនាស់ គឺជាលទ្ធផលដែលបុគ្គលគ្រប់រូបមិនចង់បាន មិនចង់ជួបឡើយ ប៉ុន្តែជាលទ្ធផលធ្វើឱ្យមនុស្សរាប់លាននាក់មានការឈឺចាប់ បែកបាក់និងស្លាប់បាត់បង់ជីវិត ធ្វើឲ្យខូចខាតទំនាក់ទំនង ។ ដូច្នេះហើយ ទំនាស់គឺជាស្ថានភាពមួយដែលមនុស្សភាគច្រើនមានការភ័យខ្លាច ។

សេដ្ឋកិច្ចកាន់តែរីកចម្រើន តម្រូវការនិងការផ្គត់ផ្គង់ទំនិញនិងសេវាកម្មនានាកាន់តែកើនឡើងនាំឲ្យមានទំនាស់កាន់តែច្រើនឡើងដែរ ចំនួនអ្នកត្រូវការសេវាកម្មដោះស្រាយទំនាស់ក៏មានការកើនឡើង ។ ប៉ុន្តែវាជាផលវិជ្ជមានដែលទំនាស់គឺជាស្ថានភាពមួយដែលគេអាចគ្រប់គ្រង និងអាចដោះស្រាយបានជាបណ្តើរៗ ។ ទំនាស់នៅក្នុងស្ថានភាពមិនល្អ គឺជាជំរើសរបស់គូភាគីអាចរកឱកាសដើម្បីកែលំអស្ថានការណ៍ ឬក៏ទំនាក់ទំនងរបស់ពួកគេ អ្វីដែលសំខាន់គឺការយល់ដឹងពីជំនាញនៃការបង្កាទំនាស់ ការទប់ស្កាត់ទំនាស់ ការគ្រប់គ្រងទំនាស់និងការដោះស្រាយទំនាស់។

បច្ចុប្បន្ននេះ មិនទាន់មានលិខិតបទដ្ឋានគតិយុត្តច្បាស់លាស់ពាក់ព័ន្ធនឹងការដោះស្រាយវិវាទនៅមូលដ្ឋាន(នៅរដ្ឋបាលថ្នាក់ក្រោមជាតិ)នៅឡើយ មានតែជាលក្ខណៈឯកទេសកម្មមួយចំនួនដែលជាហេតុធ្វើ

ឲ្យមានការសិក្សានេះត្រូវបានធ្វើឡើង ដើម្បីដោះស្រាយបញ្ហាទាំងឡាយដែលបានលើកឡើងនិងធ្វើឲ្យស្ថានភាពទទួលបានយុត្តិធម៌មានភាពល្អប្រសើរឆ្លើយតបបានចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍នៅមូលដ្ឋានផ្តល់សេវាកម្មឲ្យកាន់តែប្រសើរនិងកាត់បន្ថយភាពក្រីក្រ ដោយអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ បានលើកឡើងយ៉ាងច្បាស់ពីអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្តេជ្ញាចិត្តយ៉ាងមុតមាំដើម្បីជំរុញដំណើរការកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ក្នុងចំណោមយុទ្ធសាស្ត្រទាំង៧ ដែលបានដាក់ចេញដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ដែលបានបង្កើតឡើងនៅខែមិថុនា២០០២គឺមានទិសដៅជាយុទ្ធសាស្ត្រក្នុងការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដើម្បីផ្តល់ការដោះស្រាយវិវាទឱ្យបានឆាប់រហ័ស និងងាយស្រួលដល់ភាគីពាក់ព័ន្ធហើយនិងជួយសម្រាលដល់បន្ទុករបស់ប្រព័ន្ធតុលាការ ។ រាជរដ្ឋាភិបាលបាននិងកំពុងបន្តជំរុញលើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ជូនប្រជាពលរដ្ឋដើម្បីលើកស្ទួយនិងពង្រឹងវប្បធម៌នៃការរួមរស់ជាមួយគ្នាប្រកបដោយសន្តិភាព សាមគ្គីភាព និងសុខដុមរមនាក្នុងសង្គម។

## ២. គោលបំណង

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីធ្វើការសិក្សាស្រាវជ្រាវនិងរៀបចំលិខិតបទដ្ឋានស្តីពីការដោះស្រាយវិវាទនៅមូលដ្ឋាន(នៅរដ្ឋបាលថ្នាក់ក្រោមជាតិ)ស្ថានភាពទូទៅនៃទំនាស់ជាក់ស្តែង ដោយមានការសិក្សាស្រាវជ្រាវលិខិតបទដ្ឋានពាក់ព័ន្ធនានានិងដោយការចុះសិក្សាស្រាវជ្រាវដល់ទីកន្លែងជាក់ស្តែង តាមរយៈការប្រើបញ្ជីសំណួរ និងការអង្កេតជាក់ស្តែងដើម្បីប្រមូលព័ត៌មានលម្អិតអំពីគោលការណ៍និងនីតិវិធីនៃការដោះស្រាយទំនាស់និងការគ្រប់គ្រងទំនាស់នៅថ្នាក់ក្រោមជាតិពីអាជ្ញាធរដែនដី អង្គការ សមាគមដែលធ្វើការពាក់នឹងការដោះស្រាយវិវាទនៅមូលដ្ឋាននិងពីអ្នកពាក់ព័ន្ធផ្សេងៗទៀត។

គោលបំណងដ៏សំខាន់មួយទៀត គឺដំណើរទស្សនកិច្ចសិក្សានៅប្រទេសរីកចំរើនអំពីយន្តការនិងលិខិតបទដ្ឋាននានាស្តីពីការដោះស្រាយវិវាទនៅមូលដ្ឋានជាការចាំបាច់ដើម្បីឲ្យមានការយល់ដឹងជាលក្ខណៈសាកល។

## ៣.គោលដៅ

ការសិក្សាស្រាវជ្រាវនេះមានគោលដៅគឺ ការបង្កើតលិខិតបទដ្ឋានស្តីពីនីតិវិធីនៃការដោះស្រាយវិវាទនៅមូលដ្ឋាន(នៅរដ្ឋបាលថ្នាក់ក្រោមជាតិ) ដែលមានភាពសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ច សង្គមក្នុងពេលបច្ចុប្បន្ននិងការវិវត្តន៍ក្នុងពេលអនាគតដោយលើកកម្ពស់នូវការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដើម្បីធានាឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅរដ្ឋបាលមូលដ្ឋាន និងធានាបាននូវគុណភាពនៃការផ្តល់សេវាសាធារណៈឲ្យកាន់តែប្រសើរក្នុងការចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្ការទំនាស់ ការទប់ស្កាត់ទំនាស់ការគ្រប់គ្រងទំនាស់និងការដោះស្រាយទំនាស់របស់ប្រជាពលរដ្ឋ។

## ៤.វិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវ

ដើម្បីឲ្យក្រុមបច្ចេកទេសចុះសិក្សាស្រាវជ្រាវ ប្រមូលទិន្នន័យនិងយន្តការស្ដីពីការដោះស្រាយវិវាទនៅមូលដ្ឋាន រៀបចំគោលការណ៍ និងនីតិវិធីឲ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយនោះ ការសិក្សាស្រាជ្រាវនេះត្រូវធ្វើឡើងតាមរយៈវិធីសាស្ត្រចំនួនបីគឺ ៖

### ៤.១.ប្រមូលចងក្រងនូវលិខិតបទដ្ឋានពាក់ព័ន្ធដែលមានស្រាប់ ដូចជាច្បាប់ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានគតិយុត្តនៃការដោះស្រាយវិវាទឬទំនាស់នៅក្នុងបរិបទកម្ពុជា

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវតាមរយៈការអានច្បាប់ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការសម្រុះសម្រួលទំនាស់នៅក្នុងបរិបទកម្ពុជា មានដូចខាងក្រោម៖

*ច្បាប់ស្ដីពីអស្សាមិករណ៍ ២៦-០២-២០១០*

មាត្រា៣២"គណៈកម្មាធិការអស្សាមិករណ៍ និង គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាមានសមត្ថកិច្ចពិនិត្យនិងដោះស្រាយបណ្ដឹងតវ៉ា"។

មាត្រា៣៣ ម្ចាស់អចលនវត្ថុ និង ឬ ម្ចាស់សិទ្ធិដែលមិនយល់ស្របនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍អាចប្ដឹងទៅគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា។

វាក្យខ័ណ្ឌទី១នៃមាត្រា៣៤ "ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្ដឹង ម្ចាស់អលនវត្ថុនិងឬ/ ម្ចាស់សិទ្ធិអាចប្ដឹងទៅតុលាការមានសមត្ថកិច្ចចំពោះ នីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និងយុត្តិធម៌។"

វាក្យខ័ណ្ឌទី២ នៃមាត្រា៣៤ "បែបបទ និងនីតិវិធីប្ដឹងត្រូវកំណត់ដោយអនុក្រឹត្យ"។

*តំបន់ការពារធម្មជាតិ ១៥-០២-២០០៨*

មាត្រា៥១ "មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដែលមានសមត្ថកិច្ចមានសិទ្ធិផ្អាកសកម្មភាពទាំងមូល ឬ មួយផ្នែកជាបណ្ដោះអាសន្នរបស់បុគ្គលណាដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬបំពានលើកិច្ចសន្យា រហូតដល់ដំណោះស្រាយវិវាទត្រូវបានបញ្ចប់"។

វាក្យខ័ណ្ឌទី១មាត្រា៥២ "បុគ្គលណាមិនពេញចិត្តចំពោះការសម្រេចណាមួយ ដែលធ្វើឡើងដោយមន្ត្រីពាក់ព័ន្ធនឹងការពិន័យអន្តរការណ៍ដូចមានចែងក្នុងមាត្រា៥៤ មាត្រា៥៦ ចំណុច១នៃមាត្រា៥៧ មានសិទ្ធិធ្វើពាក្យបណ្ដឹងតវ៉ាមកប្រធានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិថ្នាក់កណ្ដាល ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ យ៉ាងយូរគិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេចរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់កើតហេតុ ឬប្ដឹងទៅតុលាការ"។

*ច្បាប់ស្ដីពីសម្បទាន ១៩-១០-២០០៧*

វាក្យខ័ណ្ឌទី១នៃមាត្រា៣៩ "វិវាទរវាងស្ថាប័នជាប់កិច្ចសន្យានិងសម្បទានិកត្រូវដោះស្រាយដោយអនុលោមទៅតាមយន្តការដោះស្រាយវិវាទដែលបានកំណត់នៅក្នុងកិច្ចសន្យាសម្បទាន ដោយរាប់បញ្ចូលទាំងការដោះស្រាយតាមរយៈមជ្ឈត្តករអន្តរជាតិប្រសិនបើមានការព្រមព្រៀងរបស់គូភាគី។"

វាក្យខ័ណ្ឌទី២នៃមាត្រា៣៩ "សេចក្តីសម្រេចដែលចេញដោយតុលាការមានសមត្ថកិច្ច ឬដោយមជ្ឈត្តករស្របទៅតាមមាត្រានេះត្រូវមានសុពលភាពនិងត្រូវអនុវត្តដោយស្ថាប័នជាប់កិច្ចសន្យា និងសម្បទានិកអនុលោមទៅតាមខ្លឹមសារនៃសេចក្តីសម្រេចនោះ"។

*ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ១០-០៨-២០០៧*

មាត្រា៨ "មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញាកាលណាច្បាប់ដោយឡែកបានចែង ដោយជាក់លាក់នោះបណ្តឹងអាជ្ញា ក៏អាចផុតរលត់បានដែរ ១.ដោយការសម្របសម្រួលជាមួយរដ្ឋ ។ ២.ដោយការដកពាក្យបណ្តឹងនៅក្នុងករណីដែលពាក្យបណ្តឹងនេះជាល័ក្ខខ័ណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ ។ ៣.ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។"

*ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ២៩-០៦-២០០៧*

វាក្យខ័ណ្ឌទី១នៃមាត្រា១៨ "លើរាល់ការសម្រេចរបស់មន្ត្រីមានសមត្ថកិច្ចនៃក្រសួងធនធានទឹក និងឧតុនិយម អ្នកកាន់អាជ្ញាប័ណ្ណទឹកមានសិទ្ធិតវ៉ាទៅប្រធានស្ថាប័នក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលចេញសេចក្តីសម្រេចខាងលើនេះ។ ពាក្យតវ៉ាត្រូវបញ្ជាក់ឱ្យបានច្បាស់ពីមូលហេតុ។"

វាក្យខ័ណ្ឌទី២នៃមាត្រា១៨ "ក្នុងករណីមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់ក្រសួង អ្នកកាន់អាជ្ញាប័ណ្ណអាចធ្វើបណ្តឹងទៅតុលាការតាមច្បាប់។

*ច្បាប់ស្តីពីជលផល ២១-០៥-២០០៦*

មាត្រា៨៤ "មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិផ្អាកសកម្មភាពនេសាទនៅក្នុងទីតាំងនេសាទទាំងមូល ឬ មួយផ្នែកជាបណ្តោះអាសន្នដើម្បីចាត់ការតាមនីតិវិធីក្នុងករណីរូបវន្តបុគ្គលឬនីតិបុគ្គលនោះប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះឬល្មើសនឹងកិច្ចសន្យា កិច្ចព្រមព្រៀងរហូតដល់ដំណោះ ស្រាយវិវាទត្រូវបានបញ្ចប់"។

វាក្យខ័ណ្ឌទី១នៃមាត្រា៨៥ "បុគ្គលណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចមានសិទ្ធិប្តឹងតវ៉ា ក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលសេចក្តីសម្រេចនេះទៅប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល"។

វាក្យខ័ណ្ឌទី២នៃមាត្រា៨៥ "ប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ត្រូវសម្រេចលើបណ្តឹងតវ៉ានោះក្នុងរយៈពេល៣០ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹងតវ៉ានោះ ។ ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញ ដោយប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ក្នុងករណីមិនអាចទទួលយកបាន ជននោះមានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច"។

វាក្យខ័ណ្ឌទី៣នៃមាត្រា៨៥ "ការតវ៉ាក្រោមមាត្រានេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាច និងដំណើរការ

អនុវត្តច្បាប់របស់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច ក្រោមច្បាប់នេះឡើយ"។

វាក្យខ័ណ្ឌទី២នៃមាត្រា៨៧ "ការពិន័យអន្តរការណ៍លើបទល្មើសជលផលអាចធ្វើបានតែក្នុងករណីជនល្មើសសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិន លើសពី១៥ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេចពិន័យ"។

វាក្យខ័ណ្ឌទី៤នៃមាត្រា៨៧ ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅៈ១.ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស។ ២.កម្រិតខូចខាតដល់បរិស្ថាន។ ៣.ចំនួននៃការប្រព្រឹត្តបទល្មើស។៤.បរិមាណប្រាក់ពិន័យដែលធ្វើឲ្យរាងចាល។ ៥.ការប្រព្រឹត្តល្មើសដោយចេតនា។

*ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋ ប្រជាមានិត ប្រជាធិបតេយ្យឡាវស្តីពីបត្យាប័ន ១៦-០៣-២០០៥*

ប្រការទី២១ "រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬការបកស្រាយនៃសិទ្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ឬការចរចា"។

*ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា២៤-០៣-០០៣*

វាក្យខ័ណ្ឌទី១នៃមាត្រា២០ថ្មី "វិវាទដែលទាក់ទងទៅនឹងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ពាក់ព័ន្ធទៅនឹងសិទ្ធិ និងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នេះ លើកលែងតែករណីទាក់ទងនឹងវិវាទដីធ្លីត្រូវដោះស្រាយដោយសម្រុះសម្រួលគ្នា តាមដែលអាចធ្វើទៅបានតាមរយៈការពិគ្រោះយោបល់គ្នារវាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អ្នកវិនិយោគ និងភាគីណាមួយផ្សេងទៀតដែលពាក់ព័ន្ធក្នុងវិវាទ"។

វាក្យខ័ណ្ឌទី២នៃមាត្រា២០ថ្មី "ក្នុងរយៈពេលពីរខែ បន្ទាប់ពីកាលបរិច្ឆេទនៃសំណើជាលាយលក្ខណ៍អក្សរដំបូង ដែលស្នើសុំធ្វើការពិគ្រោះយោបល់គ្នានេះប្រសិនបើភាគីវិវាទពុំអាចដោះស្រាយតាមការសម្រុះសម្រួលគ្នាទេ ភាគីណាមួយអាចលើកវិវាទទៅៈ ១. នៅចំពោះមុខក្រុមប្រឹក្សាសុំការផ្សះផ្សាសម្រួលអភិវឌ្ឍន៍កម្ពុជា។ ២.សុំធ្វើមជ្ឈត្តវិនិច្ឆ័យពីក្នុងឬក្រៅប្រទេសកម្ពុជាតាមការព្រមព្រៀងរបស់គូភាគីឬ ៣.សុំការជំនុំជម្រះពីសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា។

*ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ១៧-១១-២០០២*

វិវាទកម្មទាក់ទិននឹងការបោះឆ្នោតនិងយន្តការដោះស្រាយវិវាទ។

*ច្បាប់ស្តីពីព្រៃឈើ ៣១-០៨-២០០២*

វាក្យខ័ណ្ឌទី១នៃមាត្រា៩០ "ទណ្ឌកម្មក្នុងបទល្មើសព្រៃឈើមាន៖ទោសជាប់ពន្ធនាគាររឹបអូសវត្ថុតាងពិន័យដោយតុលាការ ពិន័យអន្តរកាណ៍ ការជួសជុលការខូចខាត ការព្រមាន ការដកហូត ឬការព្យួរកិច្ចព្រមព្រៀងឬលិខិតអនុញ្ញាត"។

វាក្យខ័ណ្ឌទី២នៃមាត្រា៩០ "ការពិន័យអន្តរការណ៍ លើបទល្មើសព្រៃឈើ ការជួសជុលការខូចខាត និងការព្រមាន ជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬ

ជួសជុលការខូចខាត រដ្ឋបាលព្រៃឈើអាចបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ។"

វាក្យខ័ណ្ឌទី១នៃមាត្រា៩១ "រដ្ឋបាលព្រៃឈើ មានសិទ្ធិសម្រេចពីពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើដូចមានចែងក្នុងមាត្រា៩៦នៃច្បាប់នេះ ។ ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ អាចធ្វើបានតែក្នុងករណី ជនល្មើសសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យ ស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិនឱ្យលើសពី១៥ ថ្ងៃគិតពីថ្ងៃចេញសេចក្តីសម្រេច។"

វាក្យខ័ណ្ឌទី៣នៃមាត្រា៩០ "ក្នុងករណីការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅៈ ១.ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស ។ ២.កម្រិតខូចខាតដល់បរិស្ថាន។ ៣.ចំនួននៃការប្រព្រឹត្តបទល្មើស ។ ៤.បរិមាណប្រាក់ពិន័យដែលធ្វើឲ្យរាងចាល ។ ៥.ការប្រព្រឹត្តល្មើសដោយចេតនា។

*ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ១៩-០៨-២០០២*

មាត្រា៣១ "វិវាទ ឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនិងបទបញ្ជាខាងវិស័យរបបសន្តិសុខសង្គមរវាងសមាជិក ប.ស.ស.និយោជក និង ប.ស.ស.ដែលមិនអាចដោះស្រាយបានដោយការផ្សះផ្សាររបស់គណៈកម្មការដោះស្រាយវិវាទឬបណ្តឹងនៃប.ស.ស. ត្រូវនៅក្រោមសមត្ថកិច្ចនៃតុលាការដែលសមាជិកប.ស.ស. ឬនិយោជករស់នៅ ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គមត្រូវចេញប្រកាសកំណត់អំពីសមាសភាព និងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស."។

មាត្រា៣២ ១.ត្រូវបង្កើតឱ្យមានប្រព័ន្ធសម្របសម្រួលមួយរវាងផ្នែកនីមួយៗ ដែលបង្កើតឡើង ដោយច្បាប់នេះ ជាមួយនឹងគ្រប់របបធានារ៉ាប់រងនៃផ្នែកសាធារណៈ ដើម្បីឱ្យមានសុពលភាពក្នុងការចូលនិវត្តន៍នៃសេវាដែលមានពីមុនមក និងមានសុពលភាពនៃរយៈពេលធានារ៉ាប់រងក្នុងករណីមានការផ្លាស់ប្តូរលក្ខន្តិកៈ ឬរបបធានារ៉ាប់រងនៃភ្នាក់ងារណាមួយ។២.បែបបទនៃការអនុវត្តប្រព័ន្ធសម្របសម្រួលនេះ ត្រូវកំណត់ដោយប្រកាសនៃរដ្ឋមន្ត្រីទទួលបន្ទុករបបសន្តិសុខសង្គម។

*ច្បាប់ស្តីពីការគ្រប់គ្រងនិងការធ្វើអាជីវកម្មធនធានរ៉ែ ១៣-០៧-២០០១*

ចំណុចត្រៃទី៣ វាក្យខ័ណ្ឌទី៣នៃមាត្រា២៥ "ក្នុងករណីម្ចាស់ដី និងសម្បទានិកដែលបានទទួលអាជ្ញាប័ណ្ណធនធានរ៉ែមិនអាចសម្រុះសម្រួលគ្នាលើសំណងបាននោះទេរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវសម្រួលដោះស្រាយហើយ បើមិនបានសម្រេចទេ ត្រូវធ្វើសំណើទៅរាជរដ្ឋាភិបាល ដើម្បីបង្កើតគណៈកម្មការចម្រុះមួយសម្រាប់ដោះស្រាយករណីនេះ"។

ចំណុចត្រៃទី៤វាក្យខ័ណ្ឌទី៣នៃមាត្រា២៥ "ក្នុងករណីដែលភាគីទាំងសងអស់ មិនយល់ព្រមតាមដំណោះស្រាយរបស់គណៈកម្មការចម្រុះទេនោះ សេចក្តីសម្រេចជាសមត្ថកិច្ចរបស់តុលាការ"។

*ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ១៩-០៣-២០០១*

ចំណុចត្រទី៦នៃមាត្រា៤៣ "សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់ អធ្យាស្រ័យទៅវិញទៅមក" តួនាទីបម្រើកិច្ចការមូលដ្ឋានរបស់រដ្ឋបាលឃុំ សង្កាត់។

*អនុក្រឹត្យលេខ ២២អនក្រ.បក ស្តីពីការផ្ទេរមុខងារ និងកាតព្វកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ២៥-០៣-២០០២*

ចំណុចត្រទី៩នៃមាត្រា២៤ "ដោះស្រាយបញ្ហាដែលជាផលប្រយោជន៍រួមជាមួយភូមិភាគជ្រុល" ភារកិច្ចមេភូមិ។

មាត្រា៤៤ "ក្រសួងមហាផ្ទៃ ត្រូវសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់ពីរ ឬច្រើននិងជានាដោះស្រាយរាល់ទំនាស់និងជម្លោះដែលក្រុមប្រឹក្សាឃុំ សង្កត់ទាំងនោះមិនអាចដោះស្រាយបាន"។

មាត្រា៤៥ "ក្រសួងមហាផ្ទៃត្រូវសហប្រតិបត្តិការ និងពិគ្រោះយោបល់ជាមួយស្ថាប័ននានារបស់រាជរដ្ឋាភិបាល ឬអង្គការជាតិ និងអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយទំនាស់ ឬជម្លោះដែលកើតឡើង រវាងក្រសួង ស្ថាប័ន ឬអង្គការទាំងនោះ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់"។

មាត្រា៤៦ "ក្រសួងមហាផ្ទៃ ត្រូវធានាថាការសម្រុះសម្រួល ការដោះស្រាយទំនាស់ និងជម្លោះរវាង ឃុំ សង្កាត់និងក្រសួង ស្ថាប័នរាជរដ្ឋាភិបាលឬអង្គការជាតិនិងអន្តរជាតិ មានភាពយុត្តិធម៌ត្រឹមត្រូវរក្សាបាននូវផលប្រយោជន៍ទាំងសងខាង និងអនុវត្តបានត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ"។

ចំណុចត្រទី៦នៃមាត្រា៦១ "ផ្សះផ្សាការខ្វែងមតិយោបល់គ្នា ហើយជម្រុញឱ្យមានការយោគយល់ និងការអត់ឱនទៅវិញទៅមករវាងប្រជាពលរដ្ឋ" តួនាទីនិងមុខងាររបស់ឃុំ សង្កាត់។

*ប្រកាសលេខ ១៨៨២ ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មអំណាចដល់អភិបាលខេត្ត ក្រុងក្នុងការជួយគាំទ្រដល់ ក្រុមប្រឹក្សាឃុំ សង្កាត់ ១៨-០៤-២០០២*

ចំណុចត្រទី៤នៃប្រការ២៦ "ការសម្របសម្រួល និងការដោះស្រាយជម្លោះរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការខ្វែងមតិគ្នារវាងក្រុមប្រឹក្សាឃុំ សង្កាត់និងអភិបាលខេត្ត ក្រុង "តួនាទីអភិបាលខេត្ត ក្រុងដើម្បីធ្វើការកត់ត្រាត្រួតពិនិត្យនិងវាយតម្លៃ។

វាក្យខ័ណ្ឌទី១នៃប្រការ៣៨ "អភិបាលខេត្ត ក្រុង ត្រូវសម្របសម្រួល រវាងឃុំ សង្កាត់ពីរ ឬច្រើនអំពីបញ្ហាណាមួយដែលមានភាពប្រទាញប្រទង់ឬមានជម្លោះជាមួយគ្នា ហើយដែលឃុំសង្កាត់ទាំងនោះមិនអាចដោះស្រាយបាន"។

វាក្យខ័ណ្ឌទី២នៃប្រការ៣៨ "ការដោះស្រាយរបស់អភិបាលខេត្ត ក្រុង ត្រូវឈរលើមូលដ្ឋាននៃការគោរពផលប្រយោជន៍ទាំងសងខាង"។

វាក្យខ័ណ្ឌទី៣នៃប្រការ៣៨ "អភិបាលខេត្ត ក្រុង ត្រូវសហការនិងពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ឬភ្នាក់ងារពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលមានភាពប្រទាញប្រទង់ ឬជម្លោះពាក់ព័ន្ធនឹងការធ្វើ

ប្រតិភូកម្មអំណាច របស់រដ្ឋចំពោះឃុំ សង្កាត់ ឬសេចក្តីសម្រេច ឬសកម្មភាពរបស់ក្រសួង ស្ថាប័ន ឬ ភ្នាក់ងារទាំងនោះ"។

ប្រកា៣៩ "ក្នុងករណីដែលអភិបាលខេត្ត ក្រុងបាន ដោះស្រាយបញ្ហាប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នា លើមូលដ្ឋាននៃការធានាបាននូវប្រយោជន៍សម្រាប់គ្រប់ភាគី និងអ្នកពាក់ព័ន្ធទាំងអស់ ហើយអភិបាលខេត្ត ក្រុង ត្រូវធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ"។

ប្រការ៤០ "ក្នុងករណីដែលបញ្ហាណាមួយ មានភាពប្រទាញប្រទង់ ឬមានជម្លោះជាមួយគ្នាក្រោយពីបានដោះស្រាយហើយតែគូភាគីនិងអ្នកដែលពាក់ព័ន្ធនៅតែមិនស្រុះស្រួលជាមួយគ្នាអភិបាលខេត្ត ក្រុងត្រូវធ្វើសេចក្តីរាយការណ៍អំពីបញ្ហាទាំងនោះ និងផ្តល់អនុសាសន៍ដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបន្តដោះស្រាយ"។

*ច្បាប់ភូមិបាល ៣០-០៨-២០០១*

មាត្រា៤៧ "វិវាទរវាងភាគីចំពោះអចលនវត្ថុមួយនឹងត្រូវដាក់ឱ្យធ្វើការស៊ើបអង្កេត និងដោះស្រាយតាមនីតិវិធីដែលបានកំណត់ ។ លទ្ធផលនៃការស៊ើបអង្កេតត្រូវដាក់ជូនគណៈកម្មការសុរិយោដីដែលបង្កើតឡើងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គណៈកម្មការនេះ ត្រូវធ្វើសេចក្តីសម្រេចលើបដិវាទកម្មនោះ។ ក្នុងករណីមិនសុខចិត្ត គូវិវាទអាចប្តឹងទៅតុលាការបាន ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ។"

*អនុក្រឹត្យលេខ ៤៧ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការ សុរិយោដី ៣១-០៦-២០០២*

ខ្លឹមសារទាំងស្រុងអំពីឯកទេសសកម្មពាក់ព័ន្ធនឹងដីធ្លី។

*អនុក្រឹត្យលេខ ៤៦ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដីនិងសៀវភៅគោលបញ្ជីដីធ្លី ១១-០៦-២០០២*

វាក្យខ័ណ្ឌទី១នៃមាត្រា៣ "នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាល ខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យ ត្រូវតែងតាំងគណៈកម្មការរដ្ឋបាលសម្រាប់តំបន់ដែលត្រូវ ធ្វើការវិនិច្ឆ័យនោះ។

វាក្យខ័ណ្ឌទី២នៃមាត្រា៣ "១-តំណាងអភិបាលខេត្ត ក្រុងជាប្រធាន, ២-មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក, ៣- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដីនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក, ៤- អភិបាល ស្រុក ខ័ណ្ឌ ឬ តំណាង ជាសមាជិក, ៥- មេឃុំ ចៅសង្កាត់ ឬតំណាង ជាសមាជិក, ៦- មេភូមិ ឬតំណាង ជាសមាជិក, ៧- ចាស់ព្រឹទ្ធាចារ្យក្នុងទី តាំងធ្វើការវិនិច្ឆ័យ ២ រូប ជាមាជិក។"

វាក្យខ័ណ្ឌទី៣នៃមាត្រា៣ "ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមានៈ ១-បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី, ២- ទទួលរាល់បណ្តឹងតវ៉ាធ្វើការ

ស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង, ៣-ធ្វើសេចក្តីសន្និដ្ឋាន ផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ និង៤-លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ជូនកម្មសិទ្ធិករឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ"។

*ប្រកាសលេខ ១១២ ដនស ប្រក ស្តីពីគោលការណ៍ណែនាំនិងនីតិវិធី របស់គណៈ កម្មការ សុរិយោដី ២១-០៨-២០០២*

ខ្លឹមសារទាំងស្រុងអំពីឯកទេសកម្មពាក់ព័ន្ធនឹងដីធ្លី។

*ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ១៩-០៣-២០០១*

វិវាទកម្មនិងការដោះស្រាយវិវាទកម្មនៃការបោះឆ្នោតឃុំ សង្កាត់។

*ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសិទ្ធិសញ្ញាស្តីពីបត្យាប័ន រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិត ចិនស្តីពីបត្យាប័ន ២៥-០៧-២០០០*

ប្រការទី២០"រាល់វិវាទ ដែលកើតចេញពីការអនុវត្តន៍ ឬការបកស្រាយនៃសិទ្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬការចរចា"។

*ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃស្តីពី បត្យាប័ន ១៩-០៧-១៩៩៩*

ប្រការទី២១ "រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬការបកស្រាយនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬការចរចា"។

*ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ០៨-០៤-១៩៩៨*

មាត្រា២៥"ក្រុមប្រឹក្សាធម្មនុញ្ញសម្រេចអំពីវិវាទកម្មទាក់ទិននឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ"។

*ច្បាប់ស្តីពីការងារ ១៣-០៣-១៩៩៧*

១- វិវាទបុគ្គលនិងការផ្សះផ្សាជាដំបូងនៃវិវាទបុគ្គល ។ ២- ការវិវាទការងាររួមៈ ការផ្សះផ្សា និង ការសម្រេចនៃអាជ្ញាកណ្តាល។

*ច្បាប់ស្តីពីសារពើពន្ធ ២៤-០២-១៩៩៧*

មាត្រា២០ "វិធាននៃដំណោះស្រាយការតវ៉ារបស់អ្នកជាប់ពន្ធអំពីបញ្ហាសារពើពន្ធ ត្រូវកំណត់ដូចតទៅៈ ១-អ្នកជាប់ពន្ធដែលមិនពេញចិត្តនឹងការកំណត់ឡើងវិញ ឬសេចក្តីសម្រេចផ្សេងទៀត ដែលធ្វើឡើងដោយរដ្ឋបាលសារពើពន្ធអាចធ្វើការតវ៉ាទៅប្រធាននាយកដ្ឋានពន្ធដារ ។ ការតវ៉ាត្រូវមានកម្រិតព្រំដែនតែត្រឹមដើមហេតុ ឬព័ត៌មានផ្សេងទៀត ដែលមាននៅក្នុងការកំណត់ឡើងវិញ សេចក្តីសម្រេចឬនីតិវិធីនៃការកំណត់ពន្ធឡើងវិញប៉ុណ្ណោះ ។ ២-ការតវ៉ាខាងរដ្ឋបាលត្រូវធ្វើជាលាយល័ក្ខអក្សរទៅតាមទម្រង់ដែលចែងក្នុងមាត្រា១២១នៃច្បាប់នេះ និងត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធ ក្នុងរយៈពេល៣០ថ្ងៃក្រោយថ្ងៃដែលអ្នកជាប់ពន្ធទទួលលិខិតជូនដំណឹងទារបំណុលពន្ធរបស់រដ្ឋបាលសារពើពន្ធ។ ៣-ការតវ៉ាខាងរដ្ឋបាលពុំអាចធ្វើឱ្យអ្នកជាប់ពន្ធរួចផុតពីកាតព្វកិច្ចត្រូវបង់ប្រាក់ពន្ធប្រាក់ពន្ធបន្ថែមនិងការប្រាក់ផ្សេងៗ ដែលបញ្ជាក់នៅក្នុងលិខិតជូនដំណឹងទារបំណុលពន្ធឡើយ។"

មាត្រា១២១"ការតវ៉ាខាងរដ្ឋបាលអាចនឹងទទួលយកបានបើសិនជាក្នុងពាក្យតវ៉ានោះ មានខ្លឹមសារដូចខាងក្រោមៈ១-លេខអត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធដែលធ្វើពាក្យតវ៉ាបើសិនជាមាន។ ២-សេចក្តីយោងទៅរកការកំណត់សេចក្តីសម្រេចឬលទ្ធផលដែលជាកម្មវត្ថុនៃពាក្យតវ៉ា ។ ៣-ដើមហេតុឬអំពើដែល ជាកម្មវត្ថុនៃពាក្យតវ៉ា។ ៤- ហេតុផលនៃការតវ៉ា។ ៥- កាលបរិច្ឆេទ និង ហត្ថលេខារបស់អ្នកជាប់ពន្ធ និងហត្ថលេខារបស់តំណាងមានការអនុញ្ញាតរបស់អ្នកជាប់ពន្ធបើសិនជាមានភាពចាំបាច់។"

វាក្យខ័ណ្ឌទី១នៃមាត្រា១២២ "រដ្ឋបាលសារពើពន្ធត្រូវចេញសេចក្តីសម្រេចជាថ្មីក្នុងរយៈពេល៦០ថ្ងៃក្រោយពីថ្ងៃបានទទួលពាក្យតវ៉ា ដើម្បីបញ្ជាក់ភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវទាំងស្រុង ឬចំណែកណាមួយនៃការកំណត់ពន្ធ ឬសេចក្តីសម្រេចផ្សេងៗ ដែលអ្នកជាប់ពន្ធតវ៉ា។ រដ្ឋបាលសារពើពន្ធ ត្រូវបញ្ជាក់ផងដែរនូវមូលដ្ឋាននៃការតវ៉ា"។

វាក្យខ័ណ្ឌទី២នៃមាត្រា១២២"ប្រសិនបើ អ្នកជាប់ពន្ធមិនយល់ព្រមលើសេចក្តីសម្រេចថ្មីនេះ របស់រដ្ឋបាលសារពើពន្ធទេនោះ អ្នកជាប់ពន្ធអាចដាក់ពាក្យតវ៉ាទៅ គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ"។

មាត្រា១២៣"ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធត្រូវកំណត់ដោយអនុក្រឹត្យតាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ"។

មាត្រា១២៤"អ្នកជាប់ពន្ធ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចជំទាស់នឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការសម្រុះសម្រួលសារពើពន្ធ ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីបានទទួលដំណឹងស្តីពីសេចក្តីសម្រេចនោះ។ អ្នកជាប់ពន្ធ ត្រូវតំកល់ទុកនៅរតនាគារជាតិនូវប្រាក់ចំនួនស្មើនឹងប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ ដែលទាក់ទិននឹងវិវាទ តាមការកំណត់របស់រដ្ឋបាលសារពើពន្ធមុននឹងដាក់ពាក្យទៅតុលាការ។"

*ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ២៥-០១-១៩៩៦*

វាក្យខ័ណ្ឌទី២នៃមាត្រា៤៦ "អ្នកជីករុករក(បុរាណវត្ថុ) ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌទីកដីដែលនឹងជីករុករកនោះហើយលុះត្រាតែបានទទួលការស្រុះស្រួលពីភាគីទាំងអស់ទើបអាចចាប់ផ្តើមធ្វើការងាររបស់ខ្លួនបាន"។

*ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ២២-០៨-១៩៩៥*

វាក្យខ័ណ្ឌទី២នៃមាត្រា៣ "មេធាវី អាចត្រូវបានចាត់តាំងដោយគូក្តីឬថៅក្រមឱ្យបំពេញមុខងារ ជាអ្នកផ្សះផ្សាឬជាអ្នកសម្រុះសម្រួល ។ មេធាវីនឹងអាចត្រូវបានចាត់តាំងជាអាជ្ញាកណ្តាលបានលុះត្រាតែមានច្បាប់អនុញ្ញាត។"

*ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ២៦-១០-១៩៩៤*

មាត្រា៥៨ "អ្នករាជការមានសិទ្ធិប្តឹងតវ៉ាទៅតុលាការអំពីករណីដែលពាក់ព័ន្ធទៅនឹងកិច្ចការមុខងារសាធារណៈ។ ប៉ុន្តែជាការចាំបាច់អ្នករាជការនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន។"

មាត្រា៥៩"សមត្ថកិច្ចដើម្បីដោះស្រាយទំនាស់ខាងលើនេះ ត្រូវប្រគល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថាគណៈកម្មការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ដែលមានប្រធានស្ថាប័នមុខងារសាធារណៈ ជាប្រធាន ហើយនឹងមានសមាសភាពដែលកំណត់ដោយអនុក្រឹត្យ"។

*ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ០៤-០៨-១៩៩៤*

មាត្រា២០ "វិវាទដែលទាក់ទងទៅនឹងកិច្ចការវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់អ្នកវិនិយោគដែលពាក់ព័ន្ធទៅនឹងសិទ្ធិនិងកាតព្វកិច្ចដែលមានចែងនៅក្នុងច្បាប់នេះអាចៈ (១)-ដោះស្រាយដោយសម្រុះសម្រួលតាមការពិគ្រោះគ្នារវាងភាគីជម្លោះទាំងឡាយ។ (២)-ក្នុងកំឡុងពេលពីរខែបើវិវាទមិនបានដោះស្រាយតាមការសម្រុះសម្រួលគ្នាទេវិវាទនេះអាចៈ (២.១)- លើកយកមកដាក់ជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាផ្តល់យោបល់, (២.២)- ដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា, (២.៣)- ឬដោះស្រាយតាមនីតិវិធីអន្តរជាតិណាមួយតាមការព្រមព្រៀងនៃភាគី។"

*ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ២៩-០១-១៩៩៣*

វាក្យខ័ណ្ឌទី១នៃមាត្រា ៧"បណ្តឹងអាជ្ញាមិនអាចសម្រុះសម្រួលដោយកិច្ចការណាមួយឡើយ"។

*ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ២០-០៧-១៩៨៩*

វាក្យខ័ណ្ឌទី១នៃមាត្រា១៧ "បណ្តឹងទាស់នោះ (បណ្តឹងជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍) ត្រូវអ្នកប្តឹងជំទាស់ឬតំណាងរបស់ខ្លួនយកទៅជូនគណៈកម្មាធិការប្រជាជនឃុំឬសង្កាត់(ក្រុមប្រឹក្សាឃុំសង្កាត់)ខាងលំនៅអនាគតប្រពន្ធ ។ គណៈកម្មាធិការនេះ ត្រូវសម្រេចក្នុងរយៈពេល៣ថ្ងៃ គិតពីថ្ងៃទទួលបណ្តឹងទាស់។

វាក្យខ័ណ្ឌទី២នៃមាត្រា១៧ "បើអ្នកប្តឹងជំទាស់ឬអនាគតប្តីប្រពន្ធមិនសុខចិត្តនឹងសេចក្តីសម្រេចនេះ គណៈកម្មាធិការប្រជាជនឃុំឬសង្កាត់ ត្រូវបញ្ជូនសំណុំរឿងទៅតុលាការប្រជាជន (សាលាដំបូង) ក្នុងរយៈពេល៥ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹងទាស់ដើម្បីសម្រេច"។

វាក្យខ័ណ្ឌទី២នៃមាត្រា៤២ "បណ្តឹងនោះ(បណ្តឹងលែងលះគ្នា) ត្រូវដើមចោទយកទៅជូនតុលាការប្រជាជនខេត្ត-ក្រុងផ្ទាល់ក៏បានឬជូនគណៈកម្មាធិការប្រជាជនឃុំឬសង្កាត់ខាងលំនៅរបស់ចុងចម្លើយ ដោយខ្លួនឯងផ្ទាល់ក៏បាន"។

វាក្យខ័ណ្ឌទី៣នៃមាត្រា៤២"ក្នុងករណីខាងក្រោមនេះ(ករណីប្តឹងទៅគណៈកម្មាធិការប្រជាជនឃុំ ឬសង្កាត់) គណៈកម្មាធិការប្រជាជនឃុំឬសង្កាត់ត្រូវធ្វើការផ្សះផ្សា ក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីបានទទួលពាក្យបណ្តឹង ។ បើផ្សះផ្សាពុំបានសម្រេចត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការប្រជាជនខេត្ត ក្រុង"។

*ច្បាប់ស្តីពីការអប់រំ ០៧-១២-២០០៧*

វាក្យខ័ណ្ឌទី២ នៃមាត្រា៤០ "ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវចេញលិខិតបទដ្ឋានស្តីពីនីតិវិធីនៃការស្នើឬការតវ៉ានិងនីតិវិធីនៃដំណោះស្រាយ"។

*ច្បាប់ស្តីពីទេសចរណ៍ ១០-០៦-២០០៩*

ជំពូកទី ៧ ស្តីពីការដោះស្រាយវិវាទទេសចរណ៍ ។

*ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ១០-០៦-២០០៩*

មាត្រា៤០ "បទល្មើសចរាចរណ៍ ដែលមានលក្ខណៈជាបទលហុដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលចរាចរណ៍។

មន្ត្រីនគរបាលចរាចរណ៍មានសិទ្ធិសម្រុះសម្រួល ក្នុងករណីមានគ្រោះថ្នាក់ដែលបណ្តាលឲ្យសងតែសំណងខូចខាត ។ បើសិនជាការសម្រុះសម្រួលមិនបានសម្រេចមន្ត្រីនគរបាលចរាចរណ៍ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ"។

## ៤.២.សន្និដ្ឋាន

យោងតាមបទប្បញ្ញត្តិនៃច្បាប់ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានគតិយុត្តដែលបានដកស្រង់ខាងលើបានបង្ហាញឲ្យឃើញថា នីតិវិធី ឬយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែលមានយន្តការសម្រុះសម្រួល និងការផ្សះផ្សាត្រូវបានចែងនិងដាក់បញ្ចូលក្នុងក្រម ច្បាប់ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលកំពុងអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។ នីតិវិធីឬយន្តការទាំងនោះ ត្រូវបានយកមកអនុវត្តសម្រាប់ការសម្រុះសម្រួលនិងផ្សះផ្សា និងបានអន្តរាគមន៍គ្រប់ស្ថានភាពទំនាស់រដ្ឋប្បវេណីដែលមិនមែនជាករណីវិវាទព្រហ្មទណ្ឌបាន និងកំពុងកើតមានឡើងនៅគ្រប់វិស័យនានាក្នុងសង្គមកម្ពុជា។

ទោះបីជានីតិវិធី ឬយន្តការនៃការដោះស្រាយវិវាទទាំងនោះស្ថិតក្នុងក្របខ័ណ្ឌនៃការសម្រុះសម្រួល និងផ្សះផ្សាតាមបែបក្រៅប្រព័ន្ធតុលាការក្តី ក៏យន្តការនេះស្ថិតនៅក្រោមក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានជាលក្ខណៈឯកទេសកម្មមួយជាក់លាក់ដែរ និងមិនមានទំនាស់ទៅនឹងច្បាប់និងប្រព័ន្ធតុលាការកម្ពុជាទេ។

## ៤.២.ចុះសិក្សាស្រាវជ្រាវដល់ទីតាំងជាក់ស្តែងដើម្បីប្រមូលព័ត៌មាន មតិយោបល់ សេចក្តីត្រូវការនិងសំណូមពរ តាមរយៈកម្រងសំណួរនិងការអង្កេតជាក់ស្តែង ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ សាលាដំបូងខេត្ត និងអយ្យការអមសាលាដំបូងខេត្តនិងប្រជាពលរដ្ឋដែលធ្លាប់ បានទទួលសេវាកម្មដោះស្រាយក្រៅប្រព័ន្ធតុលាការនិងអ្នកពាក់ព័ន្ធនានា

### ៤.២.១.រដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត ក្រុង ស្រុក ឃុំនិងសង្កាត់)

ឆ្លងតាមការបំភ្លឺ និងតាមរយៈការសម្ភាសន៍របស់អាជ្ញាធរពាក់ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន អភិបាលរងខេត្ត សមាជិកក្រុមប្រឹក្សាខេត្ត អភិបាលរងក្រុង អភិបាលរងស្រុក សមាជិកក្រុមប្រឹក្សាស្រុក សមាជិកក្រុមប្រឹក្សាក្រុង សមាជិកក្រុមប្រឹក្សា ឃុំនិងសង្កាត់តាមរយៈសំណួរ ឃើញថាប្រភេទទំនាស់តូចតាចភាគច្រើនលើសលុប ត្រូវបានដោះស្រាយសម្រុះសម្រួលដោយរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសថ្នាក់ក្រុង ស្រុក ឃុំនិងសង្កាត់ភាគច្រើន ជាប្រភេទទំនាស់ដូចមានៈ ទំនាស់ដីធ្លី (ទំនាស់រវាងប្រជាពលរដ្ឋនិងរដ្ឋលើការចូលកាន់កាប់ដីរបស់រដ្ឋដោយខុសច្បាប់ និងការចូលកាន់កាប់ដីរដ្ឋក្នុងតំបន់ហាមឃាត់ បំពានកម្មសិទ្ធិដីធ្លីរបស់បុគ្គលបំពានកម្មសិទ្ធិដីធ្លីរបស់រដ្ឋ ការសាងសង់រំលោភច្បាប់ឬលើសពីការអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ច ទំនាស់រវាងម្ចាស់កម្មសិទ្ធិដែលមានព្រំដីជាប់គ្នា ទំនាស់ដែលកើតឡើងពីការកំណត់ព្រំដីមិនច្បាស់លាស់ ការបំពានកាន់កាប់ដីសហគមន៍ ទំនាស់ពាក់ព័ន្ធលិខិតទិញលក់ដីជាន់គ្នា២ដងឬបីដងលើដីដដែលដោយសារមិនបានចុះវាស់វែងត្រឹមត្រូវ) អំពើហិង្សា ទំនាស់ព្រំដីជាប់គ្នា វិវាទកិច្ចសន្យា (ជំពាក់ប្រាក់រឿងទិញលក់ដី វិវាទកិច្ចសន្យាជួលដី ខ្ចីប្រាក់ដោយពុំមានកិច្ចសន្យាត្រឹមត្រូវ ការលេងតុងទីន) អំពើហិង្សាក្នុងគ្រួសារ (អំពើហិង្សាកើតពីការស្រវឹងស្រា លេងល្បែងស៊ីសង ខ្វះអាហារ ភាពក្រីក្រ មិនធ្វើការផ្ទះ) អំពើហិង្សាលើបុគ្គល អំពើឆបោក ក្មេងទំនើង បទល្មើសចរាចរណ៍ ទំនាស់ដោយសារការយឺតយ៉ាវក្នុងការបើកប្រាក់សោធននិវត្តន៍របស់មន្ត្រីចូលនិវត្តន៍ ទំនាស់តវ៉ាចំពោះតំលៃទឹកភ្លើងឡើងខ្ពស់ ការធ្វើអត្តឃាតដោយផឹកថ្នាំពណ៌ខៀវ (ថ្នាំសម្លាប់សត្វល្អិត) ទំនាស់ជេរប្រមាថអ្នកជិតខាងឬទំនាស់ពាក្យសំដី អំពើ ប្រទូសកេរ្តិ៍ខ្មាស់ បណ្តឹងលែងលះ ការប្រព្រឹត្តិល្បែងស៊ីសង បទល្មើសព្រហ្មទណ្ឌ(បង្ករបួសស្នាម) អំពើបរិហារកេរ្តិ៍ ទំនាស់ បែងចែកទ្រព្យសម្បត្តិពីការលែងលះឬការបែងចែកមរតក សត្វពាហនៈ ស៊ីដំណាំអ្នកជិតខាង ឆ្កែខាំ ទំនាស់ការប្រើ ប្រព័ន្ធធារាសាស្ត្រមិនត្រឹមត្រូវតាមរបបទឹក ការធ្វើអាជីវកម្ម ឯកជនដែលបង្កផលប៉ះពាល់ដល់អ្នករស់នៅជិតខាង(ហាលជំឡុងដែលមានក្លិនស្អុយ) ការសាងសង់ទីតាំង លក់ដូរដោយមិនបានសុំការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច និងបទល្មើសព្រហ្មទណ្ឌតូចតាច (បទលហុ)ផ្សេងៗផងដែរ។

**សន្និដ្ឋាន**

ការដោះស្រាយវិវាទនៅមូលដ្ឋានគឺពឹងផ្អែកទាំងស្រុងលើក្របខ័ណ្ឌនៃការដោះស្រាយវិវាទតាមបែបប្រពៃណីដែលមានស្រាប់តាំងពីយូរយារណាស់មកហើយ គឺយន្តការសម្រុះសម្រួលនិងផ្សះផ្សាដែលអនុវត្តដោយ

ចាស់ទុំក្នុងភូមិ និងអាជ្ញាធរមូលដ្ឋានរួមមានៈ មេភូមិ មេឃុំ ចៅសង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់។ ចំណែកនៅថ្នាក់ស្រុក ក្រុងនិងខេត្ត ក៏មានយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដែរ តាមរយៈច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានចែងពីតួនាទីរបស់ក្រុមប្រឹក្សាក្នុងការជួយសម្រុះសម្រួល និងផ្សះផ្សាវិវាទនៅមូលដ្ឋានមុននឹងឡើងទៅដល់តុលាការដែរ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ផងដែរ។

តួអង្គទាំងឡាយនៅថ្នាក់ភូមិ ឃុំ សង្កាត់ និងថ្នាក់ក្រោមជាតិបានដើរតួនាទីដ៏សំខាន់បំផុត ដែលមិនអាចខ្វះបានក្នុងការឆ្លើយតបទៅនឹងវិវាទដែលបានកើតឡើងនៅមូលដ្ឋាន ។ តាមការសិក្សាស្រាវជ្រាវរបស់ អង្គការ UNDP ដោយសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌នៅឆ្នាំ២០០៥ បានបង្ហាញថា ករណីវិវាទបានកើតឡើងចំនួនប្រហែល ៤ ករណីក្នុង១ភូមិ ក្នុងឆ្នាំមួយខែ បើគិតជាមធ្យមមានចំនួន ៥៤,៧៧៦ ករណីវិវាទដែលថ្នាក់ភូមិបានទទួលក្នុង១ឆ្នាំ ដូចនេះករណីវិវាទដ៏ច្រើនលើសលុបដែលបានកើតឡើងរាល់ថ្ងៃនៅតាមមូលដ្ឋាន និងត្រូវបានគ្រប់គ្រង និងដោះស្រាយដោយដោយអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ ប្រកបដោយស្មគ្រចិត្ត យោគយល់ និងសន្តិភាព ។

## ៤.២.២.សាលាដំបូងខេត្ត និងអយ្យការអមសាលាដំបូងខេត្ត

ឆ្លងតាមការបំភ្លឺនិងតាមរយៈការសម្ភាសរបស់ប្រធានសាលាដំបូង ចៅក្រមនិងព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងអមសាលាដំបូង ខេត្តបានបញ្ជាក់ថា ប្រភេទវិវាទឬបទល្មើសតូចតាចគួរធ្វើការដោះស្រាយសម្រុះសម្រួលនៅអាជ្ញាធរ មូលដ្ឋាន ថ្នាក់ឃុំ សង្កាត់ឬស្រុក ក្រុង និងខណ្ឌរួមមាន៖ អំពើហិង្សាក្នុងគ្រួសារ(ដែលមិនទាន់ឈានដល់ការបង្ករបួសស្នាមធ្ងន់ធ្ងរ) បទលហុតូចតាច (បទបរិហារកេរ្តិ៍ឬជេរប្រមាថបន្តិចបន្តួច) អំពើហិង្សាលើបុគ្គល(ស្រាលដែលមិនចាំបាច់ឈានដល់ការសម្រេចសេចក្តី) បទល្មើសស្រវឹងជាក់ស្តែង (មិនគួរប្តឹងមកតុលាការទេគួរតែពិន័យ អន្តរការណ៍ឬធ្វើការអប់រំ) អំពើបង្កដោយក្មេងទំនើង ទំនាស់ដកព្រំដីអ្នក ជិតខាង ។ ជាមួយគ្នានេះដែរ ក៏បានលើកឡើងអំពីក្រមរដ្ឋប្បវេណី បានផ្តល់អំណាចឲ្យអាជ្ញាធមានសមត្ថកិច្ចមានសិទ្ធិដោះស្រាយវិវាទពាក់ព័ន្ធនឹងឋានៈរបស់បុគ្គលតែគួរកំណត់ឲ្យបានច្បាស់លាស់អំពីសមត្ថកិច្ច ដែលត្រូវដោះស្រាយ ។ ជាពិសេស ត្រូវមានយន្តការច្បាស់លាស់សម្រាប់ធ្វើការដោះស្រាយនៅត្រឹមថ្នាក់អាជ្ញាធរ ឃុំ សង្កាត់ឬ ស្រុក ក្រុង និងខណ្ឌបានហើយ បើក្នុងករណីដោះស្រាយសម្រុះសម្រួលមិនបានសម្រេច ទើបចាំបាច់ប្តឹងមកតុលាការរាជធានី ខេត្តតែម្តងដោយពុំចាំបាច់ប្តឹងទៅអាជ្ញាធររដ្ឋបាលថ្នាក់រាជធានី ខេត្តទេ កុំឲ្យឆ្លងកាត់ច្រើនដំណាក់ការ ប៉ុន្តែការដោះស្រាយសម្រុះសម្រួលត្រូវធ្វើយ៉ាងណាកុំឲ្យប្រាសចាកពីច្បាប់ និងក្រមព្រហ្មទណ្ឌ។

ភាគច្រើនទំនាស់រដ្ឋប្បវេណីតូចតាចឬបទល្មើសលហុតូចតាចដែលអាចធ្វើការផ្សះផ្សាបាន តុលាការមិនសូវទទួលយកមកដោះស្រាយទេ(ជាពិសេសបទលហុតែម្តង)រួមមាន៖ បណ្តឹងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងគ្រួសារ (ដែលច្រើនតែធ្វើការផ្សះផ្សានៅមូលដ្ឋានសិនក្នុងករណីមិនបានសម្រេចទើប ប្តឹងមកតុលាការ)

បទល្មើសលហុ (ដែលប្រព្រឹត្តិល្មើសនឹងបំរាមសាធារណៈ ជេរប្រមាថគ្នាឬជេរប្រមាថ មន្ត្រីរាជការសាធារណៈ បន្តិចបន្តួច លួចមាន់១ លួចចេក១ស្និត លួចដោះត្រីជាប់មង ចាក់សំរាមតាមទីសាធារណៈ ឡូឡាតាម ទីសាធារណៈ) ។ល។ ប្រភេទបទល្មើសតូចតាចបែបនេះភាគច្រើន ព្រះរាជអាជ្ញាមិនចាត់ការទេគឺប្រគល់ ឲ្យទៅអាជ្ញាធរមូលដ្ឋានធ្វើការសម្រុះសម្រួល ។ ផ្ទុយទៅវិញតុលាការចាត់ការតែ លើបទល្មើសមជ្ឈឹម ឬបទ ឧក្រិដ្ឋ ដូចជា បទឆបោក បទរំលោភលើទំនុកចិត្ត បទរំលោភសេពសន្ថវៈ ការរួមភេទជាមួយអនីតិជន បទប្លន់ បទលួចមានស្ថានទម្ងន់ទោស អំពើបេស្យាចារ ប៉ុនប៉ងមនុស្សឃាត បទមនុស្សឃាតចេតនានិង អចេតនា ការបង្កឲ្យមានរបួសស្នាមដោយចេតនា បទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចរាចរណ៍ មានលក្ខណៈធ្ងន់ធ្ងរ អំពើហិង្សាក្នុងគ្រួសារមានលក្ខណៈធ្ងន់ធ្ងរ ។ល។

**សន្និដ្ឋាន**

តាមរយៈការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌រវាងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ពីឆ្នាំ ២០០៦ដល់ឆ្នាំ២០១០ ដែលបានបង្កើតនូវមណ្ឌលសេវាកម្មយុត្តិធម៌ថ្នាក់ស្រុក ក្រុងនោះ បានបង្ហាញថា សាលាដំបូងរាជធានី ខេត្តបានយល់តិចតួចពីដំណើរការអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅ មូលដ្ឋាន ។ ស្ថាប័នតុលាការបានទាមទារយ៉ាងទទូចឲ្យមណ្ឌលសេវាកម្មយុត្តិធម៌ដែលជាស្ថាបន័ដោះស្រាយ វិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋានកសាងឲ្យបាននូវវិធានច្បាប់ នីតិវិធីនិងគោលការណ៍អនុវត្តឲ្យបាន ច្បាស់លាស់ក្នុងដំណើរការដោះស្រាយវិវាទរដ្ឋប្បវេណី និងបទលហុ ។ ការទាមទារទាំងនេះបានបង្ហាញពី ការព្រួយបារម្ភ និងការមិនទុកចិត្តរបស់ស្ថាប័នតុលាការមកលើសមត្ថភាព និងយន្តការនៃការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន។

**៤.៣.បទពិសោធន៍និងមេរៀនដែលបានអនុវត្តកន្លងមក**

ដំណោះស្រាយទាំងនោះ កន្លងមកក៏ស្ថិតក្រោមការសម្របសម្រួលដោយយកការយោគយល់គ្នា ជា លក្ខណៈប្រពៃណី ទំនៀមទំលាប់និងយកច្បាប់ធ្វើជាមូលដ្ឋាន ជាលទ្ធផលក៏ត្រូវបានប្រជាពលរដ្ឋគាំទ្រ និង ទទួលយកបាន ។ ដោយឡែកក៏មានវិវាទឬទំនាស់មួយចំនួនមិនបានដោះស្រាយឱ្យបានចប់នៅឡើយ ព្រោះ មានកត្តាប្រឈមជាច្រើន ដូចជានិតិវិធីច្បាប់ ការជាន់សមត្ថកិច្ច ការអាងខ្នងអ្នកមានលុយ អ្នកមានអំណាច ការញុះញង់ពីមជ្ឈដ្ឋាននានា សមត្ថភាពរបស់មន្ត្រីនៅមានកំរិត ខ្វះមធ្យោបាយនិងសម្ភារៈ ការយល់ដឹងរបស់ ប្រជាពលរដ្ឋនៅមានកំរិត ។ ក្នុងរយៈពេលកន្លងមកនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏បានរៀបចំឱ្យមានមន្ត្រី ទទួលបន្ទុកកិច្ចការដោះស្រាយវិវាទនៅមូលដ្ឋាននេះដែរ ដោយផ្អែកតាមការណែនាំរបស់រាជរដ្ឋាភិបាលនិង តាមរយៈលិខិតបទដ្ឋាននានាដែលមានលក្ខណៈជាឯកទេសកម្ម ។

ប្រវត្តិនៃដោះស្រាយវិវាទនៅមូលដ្ឋាន នៅសម័យសង្គមរាស្ត្រនិយមមានបង្កើតសាលាលហុ ដោយ ប្រគល់សិទ្ធិនេះទៅឱ្យរដ្ឋបាលថ្នាក់ស្រុកនិងសម័យក្រោយឆ្នាំ១៩៧៩ មានការណែនាំរបស់ក្រសួងយុត្តិធម៌ ឱ្យមានរដ្ឋបាលយុត្តិធម៌នៅថ្នាក់ឃុំ និងស្រុកដែរ កាលពីសម័យរដ្ឋកម្ពុជា។

ប៉ុន្តែមិនទាន់មានប្រព័ន្ធឬលិខិតបទដ្ឋានស្តីពីនីតិវិធីនៃការដោះស្រាយវិវាទនៅមូលដ្ឋាន ត្រូវបានគាំទ្រដោយអាជ្ញាធរតុលាការ ប៉ុន្តែបញ្ហាប្រឈមនេះ ជាការព្រួយបារម្ភបានលើកឡើងផងដែរ ដូចជាមានការលំបាកញែកឱ្យដាច់ចំពោះបទល្មើសព្រហ្មទណ្ឌមួយចំនួនដែលមានចរឹកជាបទល្មើសលហុ ឬកំណត់ឲ្យបានច្បាស់ថាអំពើណាខ្លះជាបទលហុដែលអាចសម្រុះសម្រួលបាន ឬមិនបានប៉ុន្តែបើតាមមាត្រា៨នៃក្រមព្រហ្មទណ្ឌនិងតាមក្រមនីតិវិធីព្រហ្មទណ្ឌ ជាសមត្ថកិច្ចរបស់តុលាការ ។ បញ្ហានេះអាចជាឧបសគ្គក្នុងការរៀបចំប្រព័ន្ធឬយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន ព្រោះថាតាមការប្រមើលមើលការដោះស្រាយរបស់អាជ្ញាធរមូលដ្ឋាន (ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់) ជៀសមិនផុតពីការសម្រុះសម្រួលបញ្ហានេះទេ។

ដូចនេះចង់មិនចង់អាចមានឆ្លងចូលដល់ការរំលោភសិទ្ធិអំណាច និងសមត្ថកិច្ចរបស់តុលាការឬត្រួតសមត្ថកិច្ចគ្នាជាមួយតុលាការផងដែរ ។

### សន្និដ្ឋាន

តាមរយៈរបាយការណ៍វាយតម្លៃនៃគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ដែលអនុវត្តដោយក្រសួងមហាផ្ទៃនិងក្រសួងយុត្តិធម៌ គាំទ្រដោយ UNDP ពីឆ្នាំ២០០៧ដល់ឆ្នាំ២០១០ បានបង្ហាញថា គម្រោងសិទ្ធិទទួលបានយុត្តិធម៌ដែលបានដាក់ឲ្យអនុវត្តនូវយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ឃុំ សង្កាត់ ក្រុង និងស្រុកពិតជាទទួលបានជោគជ័យ និងបទពិសោធន៍ដ៏ល្អនៃការអនុវត្តយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន និងពិតជាឆ្លើយតបទៅនឹងតម្រូវការមូលដ្ឋានពិតប្រាកដ។

របាយការណ៍ UNDP ២០១០ បានបង្ហាញថា នៅពេលដែលស្ថាប័នតុលាការតាមរាជធានី ខេត្ត បានយល់ច្បាស់ និងទទួលស្គាល់ពីតួនាទី ព្រមទាំងផ្តល់កិច្ចសហការជាមួយគ្នា ធ្វើឲ្យស្ថាប័នដោះស្រាយវិវាទនៅមូលដ្ឋានអាចអនុវត្តការដោះស្រាយវិវាទប្រកបដោយជោគជ័យ។

## ៥.សេចក្តីសន្និដ្ឋាននិងអនុសាសន៍

### ៥.១.សេចក្តីសន្និដ្ឋាន

ឆ្លងតាមការចុះសិក្សាស្រាវជ្រាវជាក់ស្តែងក្នុងបណ្តាខេត្តគោលដៅខាងលើការគ្រោងរៀបចំប្រព័ន្ធឬយន្តការដោះស្រាយវិវាទនៅមូលដ្ឋាន បានបង្ហាញឱ្យឃើញថានឹងផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនដល់សង្គម និងប្រជាពលរដ្ឋ ។ ទន្ទឹមនោះក៏ជាការចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាលក្នុងកាត់បន្ថយភាពក្រីក្រជូនប្រជាពលរដ្ឋ ដោយឡែកប្រជាពលរដ្ឋទទួលបាននូវការកាត់បន្ថយការចំណាយនានា ចំណេញពេលវេលា និងមានសាមគ្គីភាព ក្នុងសង្គមដោយសារប្រជាពលរដ្ឋភាគច្រើនជាកសិករត្រូវការពេលវេលាដើម្បីបង្កបង្កើនផល និងចំណេញថវិកា ដោយប្រជាពលរដ្ឋមិនចាំបាច់ធ្វើដំណើរទៅឆ្ងាយពីលំនៅដ្ឋានរបស់ពួកគេនឹងម្យ៉ាងទៀត ពួកគេអាចមិនចាំបាច់បង់ប្រាក់ប្រដាប់ក្តីឬអាករនានា រាល់ដំណោះស្រាយនីមួយៗសុទ្ធតែផ្អែកតាមគោលការណ៍

ព្រមព្រៀងនិងស្ម័គ្រចិត្តជានិច្ចដោយគ្មានអាជ្ញាធរណាចាប់បង្ខំឬសម្រេចសេចក្តីឡើយ ។ ការព្រមព្រៀងគ្នាជាបឋមរវាងភាគីវិវាទគឺទុកពេលវេលាមួយសម្រាប់ពួកគេគិតពិចារណាក្នុងរយៈពេលមួយសមស្រប ទន្ទឹមនឹងនោះក្នុងករណីភាគីណាមួយមិនសុខចិត្តទៅនឹងការសម្រុះសម្រួលបឋមនេះ ភាគីនោះអាចទៅរកកិច្ចអន្តរាគមន៍ពីស្ថាប័នរដ្ឋណាមួយ ឬប្រព័ន្ធយុត្តិធម៌ (តុលាការ) ក៏បាន ។

ការបង្កើត ឱ្យមានយន្តការនេះ ក៏ជួយសម្រួលដល់ការងារដល់តុលាការច្រើនដែរ ព្រោះថាតុលាការមានតែនៅថ្នាក់រាជធានី ខេត្ត ហើយម្យ៉ាងទៀតការបង់ប្រាក់ប្រដាប់ក្តីនានាក៏មានចំនួនច្រើនទៀតផង ។ ប៉ុន្តែក្នុងករណីជំលោះឬវិវាទទាំងឡាយណា ដែលថ្នាក់រដ្ឋបាលមិនអាចសម្រុះសម្រួលនិងដោះស្រាយឱ្យសះជាបានមិនត្រូវបិទសិទ្ធិប្រជាពលរដ្ឋឡើយ ពួកគេត្រូវតែមានសិទ្ធិមករកការសម្រេចសេចក្តីពីតុលាការបាន ។

## ៥.២.អនុសាសន៍

ដើម្បីជានាដល់ដំណើរការដោះស្រាយវិវាទនៅមូលដ្ឋាន ឱ្យបានរលូនសមស្របតាមសំណូមពរនិងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិនិងអាជ្ញាធរតុលាការស្នើឱ្យមានការរៀបចំលិខិតបទដ្ឋានស្តីពីនីតិវិធីនៃការដោះស្រាយវិវាទនៅមូលដ្ឋានឱ្យបានឆាប់ និងឱ្យមានការបណ្តុះបណ្តាលដល់មន្ត្រីសម្រាប់អនុវត្តការងារនេះឲ្យបានហ្មត់ចត់ ព្រោះថាកន្លងមកក៏ដូចជាបច្ចុប្បន្ននៅក្នុងរដ្ឋបាលថ្នាក់នីមួយៗមន្ត្រីដែលបម្រើការងារចំពោះកិច្ចការមានសមត្ថភាពពុំដូចគ្នានិងពុំទាន់សមស្របនៅឡើយ និងមានការខ្វះមធ្យោបាយ សម្ភារៈ និងថវិកាសម្រាប់អនុវត្តផងដែរ ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើនេះ អាជ្ញាធរតុលាការបានលើកសំណូមពរឡើងថា គួរតែ ស្នើធ្វើវិសោធនកម្មក្រមព្រហ្មទណ្ឌនិងក្រមនិតិវិធីព្រហ្មទណ្ឌត្រង់មាត្រាខ្លះ ដើម្បីផ្តល់អំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អាចបំពេញភារកិច្ចក្នុងការដោះស្រាយវិវាទនៅមូលដ្ឋានបានដោយមិនឲ្យប៉ះពាល់ដល់សមត្ថកិច្ចរបស់តុលាការ ព្រោះថាក្រមព្រហ្មទណ្ឌ ក្រមនិតិវិធីព្រហ្មទណ្ឌ ព្រមទាំងរដ្ឋធម្មនុញ្ញផងដែរបានផ្តល់សមត្ថកិច្ចក្នុងការចាត់ការគ្រប់បទល្មើសទាំងអស់រួមទាំងបទល្មើសលហុផងដែរដល់តុលាការក្នុងការជំនុំជំរះក្តីទាំងអស់នេះ ។

តាមយោបល់របស់ប្រធាន អនុប្រធានសាលាដំបូង ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងអមសាលាដំបូង អាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ បានមានមតិយោបល់គាំទ្រចំពោះការរៀបចំលិខិតបទដ្ឋានស្តីពីនីតិវិធីដោះស្រាយវិវាទនៅមូលដ្ឋាន ជាពិសេសផ្តោតទៅលើវិវាទ ឬជំលោះតូចតាចដែលជាធម្មតាអាចថ្នាក់រដ្ឋបាលនីមួយៗអាចសម្រុះសម្រួល និងដោះស្រាយបញ្ចប់បញ្ហាបាន ដោយមិនបាច់មកដល់តុលាការ ។ ចំពោះយន្តការសម្រាប់ដោះស្រាយវិវាទឬជំលោះនៅមូលដ្ឋាន ក៏បានទទួលការឯកភាពពីស្ថាប័នតុលាការ ប៉ុន្តែគួរផ្តោតជាសំខាន់ទៅលើវិវាទរដ្ឋប្បវេណី ដែលមានទឹកប្រាក់ក្នុងកំរិតសមស្របណាមួយ (ជំពាក់ប្រាក់ត្រឹមកំរិតក្រោមមួយលានរៀល) ។

ដោយឡែកចំពោះបទល្មើសតូចតាចវិញ(បទលហុ)ត្រូវបែងចែក ឬកំណត់ឱ្យបានច្បាស់លាស់ផងដែរ ថាប្រភេទណាដែលអាចសម្រុះសម្រួលបាន និងប្រភេទណាខ្លះដែលមិនអាចសម្រុះសម្រួលបាន ពីព្រោះគ្រប់បទល្មើសលហុទាំងអស់តម្រូវឱ្យតុលាការអនុវត្តតាមក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្រុមការងារដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំលិខិតបទដ្ឋានស្តីពីការដោះស្រាយវិវាទនៅមូលដ្ឋាន បានរកឃើញ គោលការណ៍ នីតិវិធី ឬវិធានច្បាប់ជាក់លាក់ណាមួយដើម្បីគ្រប់គ្រង និងធានាយន្តការនៃការដោះស្រាយវិវាទនៅមូលដ្ឋាន តាមរយៈការបង្កើតយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន គឺអនុវត្តការសម្រុះសម្រួល និងផ្សះផ្សាករណីវិវាទរដ្ឋប្បវេណី និងករណីបទលហុតូចតាចដែលនឹងមិនប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខសង្គម ។ ការពិចារណាក្នុងការកំណត់ប្រភេទវិវាទរដ្ឋប្បវេណី និងបទលហុបែបណាដែលអាចដោះស្រាយបាន និងករណីវិវាទប្រភេទណាដែលស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមិនមានសមត្ថ កិច្ចធ្វើការសម្រុះសម្រួលនិងផ្សះផ្សាបាន។

ការបង្កើតយន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅមូលដ្ឋាន គួរពិចារណាក្នុងការបង្កើតឲ្យមានប្រព័ន្ធឬនីតិវិធីចង្អុលបង្ហាញករណីវិវាទពីស្ថាប័នដោះស្រាយវិវាទនៅមូលដ្ឋានតាមក្របខណ្ឌច្បាប់ និងគួរឲ្យមានការបញ្ជាក់ទទួលស្គាល់ដោយស្ថាប័នតុលាការ ដើម្បីមានសុពលភាពតាមផ្លូវច្បាប់ក្នុងការអនុវត្តនីតិវិធី។

ការបង្កើតឧបករណ៍នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គួរគិតពិចារណាក្នុងការបង្កើតយន្តការ ឬវិធានក្នុងក្របខណ្ឌគតិយុត្ត ដើម្បីតាមដាន និងគ្រប់គ្រងការអនុវត្តកិច្ចព្រមព្រៀងដែលភាគីពាក់ព័ន្ធក្នុងវិវាទបានព្រមព្រៀងដោយស្មគ្រចិត្ត ។ កិច្ចព្រមព្រៀងដែលបានកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគីវិវាទ គួរតែកំណត់ឬចងកាតព្វកិច្ចសម្រាប់ភាគីវិវាទទាំងសងខាងអនុវត្ត តែមិនមែនជាលក្ខណៈចាប់បង្ខំឡើយ។

សេចក្តីសម្រេចដែលកើតចេញពីឆន្ទៈពិតប្រាកដរបស់ភាគីវិវាទហៅថា កិច្ចព្រមព្រៀងនៃដំណោះស្រាយវិវាទរបស់ភាគីវិវាទ គួរត្រូវបានប្រថាប់ត្រាបញ្ជាក់ឲ្យមានតម្លៃនីត្យានុកូលភាព និងទទួលស្គាល់ជាផ្លូវការដោយស្ថាប័នតុលាការ ដើម្បីផ្តល់សុពលភាពអនុវត្តតាមផ្លូវច្បាប់សម្រាប់ការអនុវត្តដោយភាគីពាក់ព័ន្ធនៅមូលដ្ឋាន។

**អ្នកធ្វើរបាយការណ៍**

**មុនី ធីរៈ**